# របាយការណ៍ប្រចាំត្រីមាសទី២

(ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២)

## ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក

# ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ (លានរៀល) | ត្រីមាសទី២ ឆ្នាំ២០២២ | ឆ្នាំ២០២១ |
|---|---|---|
| ទ្រព្យសកម្មសរុប | ៤.១២៥.១១៩ | ៤.០១៥.០៤១ |
| បំណុលសរុប | ៣.៣៧៤.១៤១ | ៣.៣០៦.៨១៧ |
| មូលធនសរុប | ៧៥០.៩៧៧ | ៧០៨.២២៤ |
| **លទ្ធផលហិរញ្ញវត្ថុ (លានរៀល)** | **ត្រីមាសទី២ ឆ្នាំ២០២២** | **ត្រីមាសទី២ ឆ្នាំ២០២១** |
| ចំណូលសរុប | ៧៨.១៤១ | ៧៧.២៦៤ |
| ចំណេញ(ខាត)មុនបង់ពន្ធ | ២៧.៥៣១ | ១៨.៨០៨ |
| ចំណេញ(ខាត)សុទ្ធក្នុងការិយបរិច្ឆេទ | ២១.៦៩៣ | ១៥.១២៩ |
| លទ្ធផលម្អិតក្នុងការិយបរិច្ឆេទ | ២៣.២០៥ | ១៦.៧៣៨ |
| **អនុបាតហិរញ្ញវត្ថុ (%)** | **ត្រីមាសទី២ ឆ្នាំ២០២២** | **ឆ្នាំ២០២១** |
| អនុបាតសាធនភាព ❶ | ២០,៨០ | ១៩,១៩ |
| អនុបាតបំណុលធៀបនឹងមូលធន | ៤៤៩,៣០ | ៤៦៦,៩២ |
| អនុបាតក្របខ័ណ្ឌសន្ទនីយភាព ❶ | ១០៣,០៦ | ១២៥,៤៦ |
| អនុបាតឥណទានមិនដំណើរការ ❷ | ៥,១៤ | ១,៨២ |
| អនុបាតឥណទានធៀបនឹងប្រាក់បញ្ញើ | ៩៧,៦២ | ៩៧,០៨ |
| **អនុបាតផលចំណេញ (%)** | **ត្រីមាសទី២ ឆ្នាំ២០២២** | **ត្រីមាសទី២ ឆ្នាំ២០២១** |
| អនុបាតចំណេញធៀបនឹងទ្រព្យសកម្ម (ROA) | ២,២៦ | ១,៦៦ |
| អនុបាតចំណេញធៀបនឹងមូលធន (ROE) | ១២,៣៩ | ១០,១៤ |
| អនុបាតលទ្ធភាពបង់ប្រាក់ | ៨៨៥,១៤ | ៦៩៣,៤៨ |
| ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | មិនមាន | មិនមាន |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | មិនមាន | មិនមាន |
| អនុបាតហិរញ្ញវត្ថុសំខាន់ៗផ្សេងទៀត | មិនមាន | មិនមាន |

សំគាល់ :

❶ : អនុលោមទៅតាមបទបញ្ញត្តិគណនេយ្យដែលចេញដោយធនាគារជាតិនៃកម្ពុជា

❷ : ឥណទានមិនដំណើរការអនុលោមទៅតាមបទបញ្ញត្តិគណនេយ្យដែលចេញដោយធនាគារជាតិនៃកម្ពុជាចំណាត់ថ្នាក់សំវិធានធន ២០% - ១០០%

# ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប









# សមាសភាពក្រុមប្រឹក្សាភិបាល



**YIM, Yong Taick**

ប្រធានក្រុមប្រឹក្សាភិបាល



**SIM, Sang Ton**

សមាជិក



**Kim, Sung Chul**

សមាជិក



**PARK, Chong Tae**

សមាជិកឯករាជ្យ



**LEE, Myunsang**

សមាជិកឯករាជ្យ

# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

ខ្ញុំបាទពិតជាមានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំង ក្នុងការបង្ហាញពីលទ្ធផលហិរញ្ញវត្ថុ របស់ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ក្នុងត្រីមាសទី២ ឆ្នាំ២០២២ ដោយអនុវត្តតាមតម្រូវការរបស់និយ័តករមូលបត្រកម្ពុជា (ន.ម.ក)។

ការរាតត្បាតនៃមេរោគកូវីដ-១៩ បង្ហាញពីបញ្ហាប្រឈមដែលមិនធ្លាប់មានពីមុនមកសម្រាប់សង្គមទាំងអស់នៅជុំវិញពិភពលោក។ ការអន្តរាគមន៍ដែលមិនមែនជាឱសថ ត្រូវបានអនុវត្តដោយរដ្ឋាភិបាល ក្នុងគោលបំណងការពារប្រព័ន្ធសុខាភិបាល ដោយកំណត់កម្រិតអត្រានៃការឆ្លង។ ទោះបីជាយ៉ាងណាក៏ដោយ វិធានការទាំងនេះបានប៉ះពាល់ដល់ជីវភាពរស់នៅ និងសុខុមាលភាពរបស់មនុស្សរាប់លាននាក់ជុំវិញពិភពលោក ដោយបានដាក់ផលប៉ះពាល់ដល់សេដ្ឋកិច្ចសង្គមដែលបណ្តាលមកពីការរាតត្បាតនៃមេរោគកូវីដ-១៩ ឲ្យស្ថិតក្រោមការត្រួតពិនិត្យនិងយកចិត្តទុកដាក់។ កម្ពុជាក៏បានបង្ហាញពីភាពជោគជ័យយ៉ាងខ្លាំងក្នុងការដាក់ឱ្យនៅដាច់ដោយឡែកករណីកូវីដ-១៩ ហើយថែមទាំងបានកាត់បន្ថយអត្រាកើតឡើងមកនៅត្រឹមសូន្យអស់រយៈពេលជាច្រើនខែជាប់គ្នា។

សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ត្រូវបានព្យាករណ៍ថានឹងកើនឡើង ៥,៣ % ក្នុងឆ្នាំ២០២២ និង ៦,៥ % ក្នុងឆ្នាំ២០២៣។ កំណើនសេដ្ឋកិច្ចកម្ពុជាបានស្ទុះងើបឡើងវិញប្រមាណ ៣.0% ក្នុងឆ្នាំ២០២១ បន្ទាប់ពីធ្លាក់ចុះ ៣.១% ក្នុងឆ្នាំ២០២០។ រដ្ឋាភិបាលបានអនុវត្តគោលនយោបាយកាត់បន្ថយផលប៉ះពាល់ពីភាពអវិជ្ជមាននៃមេរោគកូវីដ-១៩ លើអាជីវកម្ម និងប្រាក់ចំណូលរបស់ប្រជាជន ក៏ដូចជាដើម្បីគាំទ្រដល់ការស្តារសេដ្ឋកិច្ចឡើងវិញ។ ការចាក់វ៉ាក់សាំងយ៉ាងទូលំទូលាយប្រឆាំងនឹងមេរោគកូវីដ-១៩ បានអនុញ្ញាតឱ្យប្រទេសនេះបើកព្រំដែនរបស់ខ្លួនឡើងវិញសម្រាប់ពាណិជ្ជកម្ម និងទេសចរណ៍ ដែលនាំឱ្យមានការរំពឹងទុកសេដ្ឋកិច្ចជាវិជ្ជមានសម្រាប់ឆ្នាំនេះ និងឆ្នាំ២០២៣។ ទិន្នផលឧស្សាហកម្មត្រូវបានគេរំពឹងថានឹងកើនឡើង ៨,១% ក្នុងឆ្នាំ២០២២ និង៩,១% ក្នុងឆ្នាំ២០២៣។ កំណើននេះក៏នឹងត្រូវបានជំរុញដោយការអនុវត្តយុទ្ធសាស្រ្តអភិវឌ្ឍន៍សម្លៀកបំពាក់ ស្បែកជើង និងទំនិញសម្រាប់ការធ្វើដំណើរ ដើម្បីបង្កើនការប្រកួតប្រជែងនៅក្នុងវិស័យនេះ។ ការនាំចេញទំនិញ និងសេវាកម្មត្រូវបានព្យាករណ៍ថានឹងកើនឡើងនៅឆ្នាំ២០២២ និង២០២៣ លើតម្រូវការខាងក្រៅដ៏រឹងមាំសម្រាប់ផលិតផលកម្ពុជា ដែលគាំទ្រដោយការងើបឡើងវិញ

នៃសេវាកម្មទេសចរណ៍។ វិស័យសេវាកម្មត្រូវបានព្យាករណ៍ថានឹងងើបឡើងវិញដល់៤,៨% នៅឆ្នាំនេះ និងកើនឡើងដល់៦,៨% ក្នុងឆ្នាំ២០២៣។ ការបើកសេដ្ឋកិច្ចឡើងវិញ និងការគ្របដណ្តប់កម្រិតថ្នាំវ៉ាក់សាំងកម្រិតខ្ពស់ នឹងអនុញ្ញាតឱ្យមានការងើបឡើងវិញបន្តិចម្តងៗ នៅក្នុងវិស័យទេសចរណ៍ ដែលវានឹងជួយដល់តម្រូវការសម្រាប់កន្លែងស្នាក់នៅ អាហារ ការដឹកជញ្ជូន និងសេវាកម្មដោយផ្ទាល់ផ្សេងទៀត។

ទោះបីជាស្ថិតក្នុងពេលវេលាដ៏លំបាកនេះក៏ដោយ ក៏ក្នុងត្រីមាសទី២ ឆ្នាំ២០២២ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានដាក់ឲ្យដំណើរការជាផ្លូវការនូវសេវាខេអេចឃ្យូអរ "PPCBank KHQR Service" និងបានធ្វើឲ្យប្រសើរឡើងនូវសេវាធនាគារចល័តពី version ២.០ ទៅ ២.៥។ម្យ៉ាងវិញទៀត ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ក៏ទទួលបាននូវការអនុញ្ញាតពីធនាគារជាតិ នៃ កម្ពុជា និងពីក្រសួងពាណិជ្ជ ដើម្បីធ្វើការផ្លាស់ប្តូរទីតាំងធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក សាខាខេត្តសៀមរាបផងដែរ។ នៅក្នុងត្រីមាសទី២នេះ ភាគទុនិក និងក្រុមប្រឹក្សាភិបាល ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានសម្រេចធ្វើការតម្លើងដើមទុនចំនួន ១២លានដុល្លារអាមេរិក តាមរយៈ ការបែងចែកប្រាក់ចំណេញរក្សាទុក បញ្ចូលទៅក្នុងដើមទុនដែលបានចុះបញ្ជី ហើយក្នុងត្រីមាសដដែលនេះ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ក៏ទទួលបាននូវការអនុញ្ញាតពីធនាគារជាតិ នៃ កម្ពុជា ក្នុងការស្នើសុំបន្ថែមមុខងារប្រតិបត្តិការចំនួន៣ សម្រាប់ការទូទាត់បន្ថែមលើសេវាធនាគារចល័ត (PPCBank Mobile Banking) និងសេវាធនាគារតាមអ៊ីនធើណែត (Corporate Internet Banking), ការបង្កើនដើមទុនចុះបញ្ជីបន្ថែមចំនួន១២លានដុល្លារអាមេរិក, ការបែងចែកភាគលាភ និងការអនុញ្ញាតពីធនាគារជាតិ នៃ កម្ពុជា និងក្រសួងពាណិជ្ជកម្មសម្រាប់ការតែងតាំង នាយក-នាយិកា សាខា។

គិតត្រឹមត្រីមាសទី២ ឆ្នាំ២០២២ កំណើននៃទ្រព្យសកម្មរបស់យើងមានការកើនឡើងប្រហែល ០,៥% គឺកើនឡើងពី ១.០០៩លានដុល្លារអាមេរិក ទៅ ១.០១៤លានដុល្លារអាមេរិក, ឥណទានមានការកើន ១,៨% ពីចំនួន ៧៦០ លានដុល្លារអាមេរិក ទៅ ៧៧៤ លានដុល្លារអាមេរិក, ប្រាក់បញ្ញើ មានចំនួន ៧៦៨ លានដុល្លារអាមេរិក និងមូលធនមានការកើនឡើង ២,១% ពី ១៨១ លានដុល្លារអាមេរិក ទៅ ១៨៥ លានដុល្លារអាមេរិក។ នេះគឺជាកំណើននៅក្នុងត្រីមាសទី២ ឆ្នាំ២០២២ ប្រៀបធៀបជាមួយត្រីមាសទី១ ឆ្នាំ២០២២ ដែលសមិទ្ធផលរបស់ពួកយើងនេះ គឺជាអត្រាជោគជ័យក្នុងចំណោមដៃគូរប្រកួតប្រជែងហិរញ្ញវត្ថុជាច្រើននៅក្នុងទីផ្សារ។

ក្នុងនាមតំណាងឲ្យក្រុមប្រឹក្សាភិបាល ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះភាគទុនិក ក្រុមប្រឹក្សាភិបាល គណៈប្រតិបត្តិទាំងអស់នៃធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក សម្រាប់ការណែនាំ និងភាពជាអ្នកដឹកនាំ, បុគ្គលិករបស់យើងទាំងអស់សម្រាប់ការចូលរួមចំណែក និងការប្តេជ្ញាចិត្ត និងអតិថិជនរបស់យើងទាំងអស់សម្រាប់ទំនុកចិត្តរបស់ពួកគេមកលើធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ជាពិសេស ធនាគារជាតិ នៃ កម្ពុជា (NBC) និងនិយ័តករមូលបត្រកម្ពុជា (SERC) សម្រាប់ដំបូន្មាន និងការគាំទ្រ។

ខ្ញុំ Yim Yong Taick សូមសម្តែងនូវការដឹងគុណចំពោះការខិតខំប្រឹងប្រែង ដោយទទួលបានលទ្ធផលជោគជ័យក្នុងអំឡុងត្រីមាសទី២ ឆ្នាំ២០២២ និងបន្តឆ្ពោះទៅរកសមិទ្ធផលដ៏ល្អប្រសើរបន្ថែមទៀតក្នុងត្រីមាសទី៣ ឆ្នាំ២០២២។

ថ្ងៃទី១១ ខែសីហា ឆ្នាំ២០២២

ហត្ថលេខា និងត្រា

YIM. Yong Taick

ប្រធានក្រុមប្រឹក្សាភិបាល

# មាតិកា

**ព័ត៌មានហិរញ្ញវត្ថុសង្ខេប** ........ 1

**ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប** ........ 2

**សមាសភាពក្រុមប្រឹក្សាភិបាល** ........ 3

**សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល** ........ 4

**ផ្នែកទី ១ - ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ** ........ 8

ក. អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ ........ 8

ខ. លក្ខណៈនៃធុរកិច្ច ........ 9

គ. ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ........ 10

**ផ្នែកទី ២ - ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច** ........ 12

ក. លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានតាមផ្នែក ........ 12

ខ. រចនាសម្ព័ន្ធចំណូល ........ 12

**ផ្នែកទី ៣ - របាយការណ៍ហិរញ្ញវត្ថុដែលបានត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ** ........ 13

**ផ្នែកទី ៤ - ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង** ........ 14

ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ........ 14

ខ. កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ ........ 16

គ. ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល ........ 18

ឃ. ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ ........ 18

ង. ផលប៉ះពាល់អតិផរណា ........ 19

ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងហិរញ្ញវត្ថុ របស់រដ្ឋាភិបាល ........ 19

**ហត្ថលេខាអភិបាលរបស់ធនាគារភ្នំពេញពាណិជ្ជ ម.ក** ........ 20

# ផ្នែកទី ១ - ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ

## ក. អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ

| | |
|---|---|
| ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ | **ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក** |
| ជាអក្សរឡាតាំង | **Phnom Penh Commercial Bank Plc.** |
| លេខកូដស្តង់ដារ | KH ២០០០១១១A46 |
| ទីស្នាក់ការ | អគារលេខ២១៧ មហាវិថីនរោត្តម សង្កាត់ទន្លេបាសាក់ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| លេខទូរស័ព្ទ | (+៨៥៥) ២៣ ៩០៩ ៩០៩/(+៨៥៥) ២៣ ៩៩៩ ៥០០ |
| គេហទំព័រ | www.ppcbank.com.kh |
| អ៊ីមែល | info@ppcb.com.kh |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | ០០០១៥៧៩៤ ចុះថ្ងៃទី២០ មេសា ២០០៨ |
| លេខអាជ្ញាបណ្ណអាជីវកម្ម | B២៣ ចេញដោយធនាគារជាតិនៃកម្ពុជា ចុះថ្ងៃទី១៦ ធ្នូ ២០១៩ |
| សេចក្តីសម្រេចអនុញ្ញាតិនិងចុះបញ្ជីឯកសារផ្តល់ព័ត៌មានលេខ | ១៩២/២០ គ.ម.ក./ស.ស.រ ចុះថ្ងៃទី០១កញ្ញា ២០២០ |
| ឈ្មោះបុគ្គលតំណាងបុគ្គលចុះបញ្ជីលក់មូលបត្រ | លោក Baek Jongil |

## ខ. លក្ខណៈនៃធុរកិច្ច

ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានចាប់ផ្ដើមប្រតិបត្តិការធនាគារនៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៨ ដែលមានទីស្នាក់ការកណ្ដាលស្ថិតនៅអគារលេខ២១៧ មហាវិថី ព្រះនរោត្តម (ផ្លូវលេខ ៤១) សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ និងទទួលបានអាជ្ញាបណ្ណពេញលេញជាធនាគារពាណិជ្ជ។ នៅខែកញ្ញា ឆ្នាំ២០១៦ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានស្វាគមន៍សម្រាប់ការចាប់ផ្ដើមថ្មីមួយជាមួយភាគទុនិកដ៏រឹងមាំ គឺ Jeonbuk Bank Co., Ltd (ជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ JB Financial Group Co. Ltd.), ក្រុមហ៊ុន Apro Financial Co., Ltd (ជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន J&K Capital Co., Ltd. ដែលស្ថិតនៅក្រោម OK Financial Group) និងក្រុមហ៊ុន JB Woori Capital Co., Ltd (ជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ JB Financial Group Co., Ltd.) ដែលមានមូលដ្ឋានស្ថិតនៅប្រទេសកូរ៉េខាងត្បូង។

នៅពេលដែលយើងបន្តកិច្ចខំប្រឹងប្រែងរបស់យើងទៅមុខទៀត យើងក៏មិនភ្លេចនឹងអបអរសាទរចំពោះភាពជោគជ័យនាពេលកន្លងមក ក្នុងការបំពេញបាននូវតម្រូវការជាច្រើនរបស់អតិថិជនក្នុងផ្នែកសេវាធនាគារ និងខិតខំស្វែងរកវិធីសាស្ត្រនានា ដើម្បីលើកកម្ពស់គុណភាពសេវារបស់យើង គាំទ្រអតិថិជនរបស់យើងទាំងក្នុងពេលបច្ចុប្បន្ន និងអនាគត។ គិតត្រឹមបំណាច់ខែមិថុនា ឆ្នាំ២០២២ ទ្រព្យសកម្មសរុបមានចំនួន ១.០១៤ លានដុល្លារអាមេរិក និងធ្វើការបម្រើអតិថិជនច្រើនជាង ១១១.០០០ នាក់ ជាមួយនឹងសាខាចំនួន ២៣ទូទាំងប្រទេស និងម៉ាស៊ីន ATMs ចំនួន៧០ (ម៉ាស៊ីន ATMs ផ្សេងៗទៀតកំពុងត្រូវបានពិចារណានៅទីតាំងសក្ដានុពលផ្សេងៗទៀតក្នុងប្រទេសកម្ពុជា)។ បន្ថែមពីនោះ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក នឹងបន្តធ្វើការផ្ដល់ ជូនដល់អតិថិជននូវសេវាដែលមានលក្ខណៈងាយស្រួល និងធ្វើការគាំទ្រដោយបណ្ដាញឌីជីថល ដែលធ្វើឲ្យអតិថិជនកាន់តែមានភាពងាយស្រួលជាមួយនឹងបទពិសោធន៍ធនាគារ។ អតិថិជនអាចធ្វើការទំនាក់ទំនងមកយើងតាមរយៈ Live Chat ក្នុងរយៈពេល២៤ម៉ោងក្នុងមួយថ្ងៃ និង៧ថ្ងៃក្នុងមួយសប្ដាហ៍ តាមរយៈបណ្ដាញឌីជីថលទាំងអស់របស់ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក។ លើសពីនេះទៅទៀត ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានបង្កើតមជ្ឈមណ្ឌលសហគ្រាសធុនតូច-មធ្យម (SME Center) ជាលើកដំបូងរបស់ខ្លួន ដែលនឹងផ្ដល់នូវផលិតផល និងសេវាSME។ សហគ្រាសធុនតូច-មធ្យម នឹងត្រូវទទួលបាន

នូវសេវាពិគ្រោះយោបល់អាជីវកម្មផងដែរ។ ពួកយើង ក៏បានពង្រីកនូវការិយាល័យបរទេស (Foreign Desk) មានដូចជា ការិយាល័យកូរ៉េ ជប៉ុន និងចិន ក៏ដូចជា ហ្គោលក្លឹប និងមជ្ឈមណ្ឌល SME ដែលនឹងផ្តល់នូវផលិតផល និងសេវា SME។ ពួកយើងពិតជាផ្តល់តម្លៃដល់អតិថិជនទាំងអស់ និងបន្តធ្វើការអភិវឌ្ឍផលិតផល-សេវារបស់ពួកយើង ដើម្បីបម្រើជូនដល់អតិថិជនឲ្យបានល្អបំផុត។

## គ. ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ

នៅថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២២ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានតម្លើង version សេវាធនាគារចល័តពី ២.០ ទៅ ២.៥ ដើម្បីធ្វើឲ្យប្រសើរឡើងនូវបទពិសោធន៍ធនាគារឌីជីថលរបស់អតិថិជន និងការបន្ថែមមុខងារ។

នៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២២ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានដាក់ឲ្យដំណើរការជាផ្លូវការនូវសេវាខេអេចឃ្យូអរ "PPCBank KHQR Service"។ ការធ្វើឲ្យប្រសើរឡើងនូវសេវាខេអេចឃ្យូអរ ភីភីស៊ីប៊ែង នឹងអនុញ្ញាតឲ្យអតិថិជនទទួលយកនូវការទូទាត់ពីធនាគារ, គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និង Wallets ផ្សេងៗ។ ខេអេចឃ្យូអរ ត្រូវបានបង្កើតឡើងសម្រាប់ការទូទាត់រាយ ដែលតម្រូវឲ្យមានតែឃ្យូអរតែមួយគត់សម្រាប់ទទួលការទូទាត់ពី Mobile Apps នៅក្នុងប្រទេសកម្ពុជា។ ការធ្វើឲ្យការទូទាត់តាមរយៈឃ្យូអរកាន់តែមានភាពសាមញ្ញ នឹងងាយស្រួលសម្រាប់ទាំងអតិថិជន និងពាណិជ្ជករទូទាត់រាយ (Merchants)។

ដើម្បីផ្តល់នូវភាពងាយស្រួលជូនដល់អតិថិជនដ៏មានតម្លៃរបស់យើង ក៏ដូចជាដើម្បីពង្រីកសកម្មភាពប្រតិបត្តិការរបស់ខ្លួន ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានសម្រេចធ្វើការផ្លាស់ប្តូរទីតាំងសាខាខេត្តសៀមរាប ដោយទទួលបានការអនុញ្ញាតពីធនាគារជាតិ នៃ កម្ពុជា ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២២ ពីអាសយដ្ឋានបច្ចុប្បន្នស្ថិតនៅ អគារលេខ ៤២៣ ភូមិវត្តបូព៌ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប ទៅអាសយដ្ឋានថ្មីស្ថិតនៅ ផ្ទះលេខ០២៧៥ ក្រុមទី១០ ផ្លូវជាតិលេខ៦ ភូមិបន្ទាយចាស់ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប។

ដើម្បីធ្វើឲ្យកាន់តែប្រសើរឡើងនូវផលិតផល និងសេវារបស់ខ្លួន ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ទទួលបានការអនុញ្ញាតពីធនាគារជាតិ នៃ កម្ពុជា បន្ថែមមុខងារប្រតិបត្តិការចំនួន ០៣ សម្រាប់ការទូទាត់

បន្ថែមលើសេវាធនាគារចល័ត (PPCBank Mobile Banking) និងសេវាធនាគារតាមអ៊ីនធើណែត (Corporate Internet Banking) ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២២ ដូចខាងក្រោម ៖

១- ការបង់ភាគទានបេឡាជាតិសន្តិសុខសង្គម (ប.ស.ស)

២- ការទូទាត់ជាមួយពាណិជ្ជករទូទាត់រាយតាមអនឡាញ និង

៣- ការបន្ថែម KHQR Code សម្រាប់ការទូទាត់។

ដើម្បីធ្វើការពង្រឹងនូវដើមទុនរបស់ខ្លួនឲ្យកាន់តែរឹងមាំ ក៏ដូចជាដើម្បីអនុលោមទៅតាមបទបញ្ញត្តិធនាគារជាតិ នៃ កម្ពុជា "សារាចរស្តីពីការអនុវត្តប្រកាស ស្តីពី ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ" ភាគទុនិក និងក្រុមប្រឹក្សាភិបាលរបស់ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានសម្រេចធ្វើការបែងចែកប្រាក់ចំណេញរក្សាទុក បញ្ចូលទៅក្នុងដើមទុនដែលបានចុះបញ្ជី ចំនួន ១២លានដុល្លារអាមេរិក កាលពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០២២។

បន្ទាប់ពីទទួលបាននូវការអនុញ្ញាតពីធនាគារជាតិ នៃ កម្ពុជា រួចមក ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានធ្វើការស្នើសុំទៅក្រសួងពាណិជ្ជកម្ម និងទទួលបានការអនុញ្ញាតពីក្រសួងពាណិជ្ជកម្មសម្រាប់ការផ្លាស់ប្តូរទីតាំងធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក សាខាខេត្តសៀមរាប ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២។

នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២២ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ទទួលបានការអនុញ្ញាតពីធនាគារជាតិ នៃ កម្ពុជា ក្នុងការបង្កើនដើមទុនចុះបញ្ជីបន្ថែមចំនួន ១២លានដុល្លារអាមេរិក ពីចំនួន ១០២លានដុល្លារអាមេរិក ដល់ចំនួន ១១៤លានដុល្លារអាមេរិក ស្មើនឹង១១៤.០០០ ភាគហ៊ុន ហើយក្នុងថ្ងៃដដែលនេះ ធនាគារជាតិ នៃ កម្ពុជា ក៏បានអនុញ្ញាតឲ្យធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ធ្វើការបែងចែកភាគលាភជូនភាគទុនិករបស់យើងខ្ញុំផងដែរ។

# ផ្នែកទី ២ - ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

## ក. លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានតាមផ្នែក

| លទ្ធផលសម្រេចបានសំខាន់ៗ | ត្រីមាសទី២ ឆ្នាំ២០២២ | ឆ្នាំ២០២១ |
|---|---|---|
| **ផ្នែកសេវាឥណទាន** | | |
| ចំនួនគណនីឥណទាន | ៧.៩៤៧ | ៧.៣០៨ |
| ឥណទានដុលសរុប (លានរៀល) | ៣.១៤៩.១៩៥ | ៣.០៣៧.៩៣១ |
| **ផ្នែកសេវាប្រាក់បញ្ញើ** | | |
| ចំនួនគណនីប្រាក់បញ្ញើ | ១៣៨.០៦៤ | ១៥៨.៥៦១ |
| ប្រាក់បញ្ញើសរុប (លានរៀល) | ៣.១២៤.១១២ | ៣.០៣២.៥៥៦ |
| **ព័ត៌មានទូទៅ** | | |
| ចំនួនសាខាបើកដំណើការ | ២៣ | ២៣ |
| ចំនួនបុគ្គលិកសរុប | ៤៦៦ | ៤៤៥ |
| ចំនួនម៉ាស៊ីន អេធីអឹម | ៧០ | ៦៨ |
| ចំនួនម៉ាស៊ីនទូទាត់ | ២៤៨ | ២៣៨ |

## ខ. រចនាសម្ព័ន្ធចំណូល

| ល.រ | ប្រភពចំណូល | ត្រីមាសទី២ ឆ្នាំ២០២២ | | ត្រីមាសទី២ ឆ្នាំ២០២១ | |
|---|---|---|---|---|---|
| | | ចំនួន (លានរៀល) | ភាគរយ (%) | ចំនួន (លានរៀល) | ភាគរយ (%) |
| ១ | ចំណូលពីការប្រាក់ | ៧៥.៤៩៣ | ៩៦,៦១ | ៧៥.៣៣៥ | ៩៧,៥០ |
| ២ | ចំណូលកម្រៃ និងជើងសារ | ២.៥៧៦ | ៣,៣០ | ៤៩៧ | ០,៦៤ |
| ៣ | ចំណូលផ្សេងៗ | ៧៣ | ០,០៩ | ១.៤៣២ | ១,៨៥ |
| **ចំណូលសរុប** | | **៧៨.១៤១** | **១០០** | **៧៧.២៦៤** | **១០០** |

# ផ្នែកទី ៣ - របាយការណ៍ហិរញ្ញវត្ថុដែលបានត្រួតពិនិត្យឡើងវិញ ដោយសវនករឯករាជ្យ

សូមមើលឧបសម្ពន្ធរបាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ។

# ផ្នែកទី ៤ - ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

ការពិភាក្សា និងវិភាគខាងក្រោមផ្តោតលើលទ្ធផលប្រតិបត្តិការ និងស្ថានភាពហិរញ្ញវត្ថុផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុរួមរបស់ ធនាគារ ភ្នំពេញពាណិជ្ជ ម.ក (PPCBank) និងក្រុមហ៊ុនបុត្រសម្ព័ន្ធ J&A (Cambodia) Investment Co., Ltd គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ ដែលត្រូវបានត្រួតពិនិត្យដោយសវនករឯករាជ្យ។ របាយការណ៍ហិរញ្ញវត្ថុរួមត្រូវបានរៀបចំស្របតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ស.រ.ហ.អ.ក) និងអនុលោមទៅតាមបទបញ្ញត្តិពាក់ព័ន្ធ និងគោលការណ៍ណែនាំផ្សេងៗដែលចេញដោយធនាគារជាតិនៃកម្ពុជា។

## ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

### ១. ការវិភាគចំណូល

ធនាគារភ្នំពេញពាណិជ្ជម.ក មានប្រភពចំណូលចំនួន៣ធំៗគឺ ចំណូលការប្រាក់ ចំណូលពីកម្រៃ និងជើងសារនិងចំណូលផ្សេងៗ។

- ចំណូលការប្រាក់រួមមាន ចំណូលការប្រាក់ពីការផ្តល់ឥណទាន ចំណូលការប្រាក់ពីការដាក់ប្រាក់បញ្ញើរនៅធនាគារ និងចំណូលការប្រាក់បានមកពីមូលបត្រវិនិយោគនានា។
- ចំណូលកម្រៃ និងជើងសាររួមមាន កម្រៃសេវាឥណទាន ចំណូលពីការផ្ទេរប្រាក់ក្នុងស្រុក និងបរទេស ចំណូលពីសេវាប្រាក់បញ្ញើ ចំណូលពីសេវាធានា និង ចំណូលពីប័ណ្ណផ្សេងៗ។
- ចំណូលផ្សេងៗ រួមមាន ចំណូលពីអត្រាប្តូរប្រាក់លើការវិនិយោគ និងចំណូលផ្សេងៗទៀត។

### ២. ការវិភាគចំណូលតាមផ្នែក

| ល.រ | ប្រភពចំណូល | ត្រីមាសទី២ ឆ្នាំ២០២២ | | ត្រីមាសទី២ ឆ្នាំ២០២១ | |
|---|---|---|---|---|---|
| | | ចំនួន (លានរៀល) | ភាគរយ (%) | ចំនួន(លានរៀល) | ភាគរយ (%) |
| ១ | ចំណូលពីការប្រាក់ | ៧៥.៤៩៣ | ៩៦,៦១ | ៧៥.៣៣៥ | ៩៧,៥០ |
| ២ | ចំណូលកម្រៃ និងជើងសារ | ២.៥៧៦ | ៣,៣០ | ៤៩៧ | ០,៦៤ |
| ៣ | ចំណូលផ្សេងៗ | ៧៣ | ០,០៩ | ១.៤៣២ | ១,៨៥ |
| **ចំណូលសរុប** | | **៧៨.១៤១** | **១០០** | **៧៧.២៦៤** | **១០០** |

ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ទទួលបានចំណូលភាគច្រើនមកពីការប្រាក់ ដែលមាន ៩៧% នៃប្រាក់ចំណូល សរុបក្នុងត្រីមាសទី២ ឆ្នាំ២០២២។

## ៣. ការវិភាគគម្លាតចំណេញដុល

ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានរៀបចំរបាយការណ៍លទ្ធផលរួមរបស់ខ្លួនក្នុងទម្រង់ជារបាយការណ៍ដែលមិនបង្ហាញពីប្រាក់ចំណេញដុល ប៉ុន្តែទម្រង់របាយការណ៍នេះអាចបង្ហាញលើចំណេញការប្រាក់សុទ្ធដែលទទួលបានមកពីចំណូលការប្រាក់សរុប ដកនឹងចំណាយការប្រាក់ ដែលនឹងត្រូវយកមកពិភាក្សានៅក្នុងចំណុចបន្ទាប់ការវិភាគ ចំណេញ(ខាត) មុនបង់ពន្ធ។

## ៤. ការវិភាគចំណេញ (ខាត) មុនបង់ពន្ធ

| សង្ខេបនៃរបាយការន៏ចំនេញខាត | ត្រីមាសទី២ ឆ្នាំ២០២២ (លានរៀល) | ត្រីមាសទី២ ឆ្នាំ២០២១ (លានរៀល) | គម្លាត (លានរៀល) | គម្លាត (ភាគរយ) |
|---|---|---|---|---|
| ចំណូលពីការប្រាក់ | ៧៥.៤៩៣ | ៧៥.៣៣៥ | ១៥៨ | ០,២១ |
| ចំណាយលើការប្រាក់ | (២៤.០៦៧) | (២៨.០០៩) | ៣.៩៤២ | (១៤,០៨) |
| **ចំណូលមកពីការប្រាក់សុទ្ធ** | **៥១.៤២៦** | **៤៧.៣២៦** | **៤.១០០** | **៨,៦៦** |
| ចំណូលកម្រៃ និងជើងសារ | ២.៥៧៦ | ៤៩៧ | ២.០៧៩ | ៤១៨,៧៨ |
| ចំណាយកម្រៃ និងជើងសារ | (៧៤០) | (១.១៣៥) | ៣៩៥ | (៣៤,៨០) |
| **ចំណូលកម្រៃនិងជើងសារសុទ្ធ** | **១.៨៣៦** | **(៦៣៨)** | **២.៤៧៤** | **(៣៨៧,៤៤)** |
| ចំណូលប្រតិបត្តិការផ្សេងៗ | ៧៣ | ១.៤៣២ | (១.៣៦០) | (៩៤,៩២) |
| ចំណាយបុគ្គលិក | (៨.០៤២) | (៨.១៧៤) | ១៣១ | (១,៦១) |
| ចំណាយប្រតិបត្តិការ | (៨.៣២៣) | (១១.៨៧២) | ៣.៥៤៩ | (២៩,៨៩) |
| ចំណាយរំលស់ | (៦.៦៩៤) | (៧.៧៦៩) | ១.០៧៥ | (១៣,៨៤) |
| **ប្រាក់ចំណេញពីប្រតិបត្តិការ** | **៣០.២៧៥** | **២០.៣០៥** | **៩.៩៧០** | **៤៩,១០** |
| ការខាតបង់លើឱនភាពនៃតម្លៃលើឧបករណ៍ហិរញ្ញវត្ថុ | (២.៧៤៤) | (១.៤៩៧) | (១.២៤៧) | ៨៣,៣១ |
| **ប្រាក់ចំណេញមុនបង់ពន្ធ** | **២៧.៥៣១** | **១៨.៨០៨** | **៨.៧២៣** | **៤៦,៣៨** |

ក្នុងត្រីមាសទី២ ឆ្នាំ២០២២ ប្រាក់ចំណេញមុនបង់ពន្ធមានចំនួន ២៧.៥៣១លានរៀល (៤៦% កើនឡើងប្រៀបធៀបទៅនឹងត្រីមាសទី២ ឆ្នាំ២០២១) ។ ការកើនឡើងនៃប្រាក់ចំណេញភាគច្រើនគឺទទួលបានមកពីការថយចុះនៃចំណាយការប្រាក់ និងការកើនឡើងនៃចំណូលកម្រៃជើងសារ។

## ៥. ការវិភាគចំណេញ (ខាត) ក្នុងការិយបរិច្ឆេទ

| សង្ខេបនៃរបាយការណ៍ចំណេញខាត | ត្រីមាសទី២ ឆ្នាំ២០២២ (លានរៀល) | ត្រីមាសទី២ ឆ្នាំ២០២១ (លានរៀល) | គម្លាត (លានរៀល) | គម្លាត (ភាគរយ) |
|---|---|---|---|---|
| ប្រាក់ចំណេញមុនបង់ពន្ធ | ២៧.៥៣១ | ១៨.៨០៨ | ៨.៧២៣ | ៤៦,៣៨ |
| ចំណាយពន្ធលើប្រាក់ចំណូល | (៥.៨៣៩) | (៣.៦៧៩) | (២.១៥៩) | ៥៨,៦៨ |
| **ប្រាក់ចំណេញសុទ្ធក្នុងគ្រា** | ២១.៦៩៣ | ១៥.១២៩ | ៦.៥៦៤ | ៤៣,៣៩ |

ក្នុងត្រីមាសទី២ ឆ្នាំ២០២២ ប្រាក់ចំណេញបន្ទាប់ពីបង់ពន្ធមានចំនួន ២១.៦៩៣លានរៀល ដែលបានកើនឡើង ៤៣% ប្រៀបធៀបទៅនឹងត្រីមាសទី២ ឆ្នាំ២០២១ ការកើនឡើងនេះមកពីការថយចុះនៃចំណាយការប្រាក់ដូចបានបកស្រាយក្នុងចំនុច៤ (ការវិភាគចំណេញ (ខាត) មុនបង់ពន្ធ)។

## ៦. ការវិភាគលទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ

| សង្ខេបនៃរបាយការណ៍ចំណេញខាត | ត្រីមាសទី២ ឆ្នាំ២០២២ (លានរៀល) | ត្រីមាសទី២ ឆ្នាំ២០២១ (លានរៀល) | គម្លាត (លានរៀល) | គម្លាត (ភាគរយ) |
|---|---|---|---|---|
| ប្រាក់ចំណេញសុទ្ធក្នុងគ្រា | ២១,៦៩៣ | ១៥,១២៩ | ៦,៥៦៤ | ៤៣.៣៩ |
| ការខាតលម្អិតផ្សេងៗ | ១,៥១២ | ១,៦០៩ | (៩៧) | (៦.០៣) |
| **ប្រាក់ចំណេញលម្អិតសរុប** | ២៣,២០៥ | ១៦,៧៣៨ | ៦,៤៦៧ | ៣៨.៦៤ |

## ៧. ការវិភាគកត្តា និងនិន្នាការដែលប៉ះពាល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុ

ការរីករាលដាលយ៉ាងឆាប់រហ័សនៃវ៉ារ្យ៉ង់ Omicron បង្ហាញថាមេរោគរាតត្បាតកូវីដ-១៩ ទំនងជានឹងបន្តរំខានដល់សកម្មភាពសេដ្ឋកិច្ចក្នុងរយៈពេលដ៏ខ្លីខាងមុខនេះ។ លើសពីនេះ ការធ្លាក់ចុះគួរឱ្យកត់សម្គាល់នៅក្នុងបណ្តាប្រទេសសេដ្ឋកិច្ចធំៗ រួមទាំងសហរដ្ឋអាមេរិក និងចិនផងដែរ នឹងមានទម្ងន់លើតម្រូវការខាងក្រៅនៅក្នុងសេដ្ឋកិច្ចដែលកំពុងរីកចម្រើន និងកំពុងអភិវឌ្ឍន៍។ ទន្ទឹមនឹងនេះដែរ ការកើនឡើងអតិផរណា ដែលប៉ះពាល់ដល់កម្មករដែលមានប្រាក់ចំណូលទាប ជាពិសេសគឺកើតចេញពីការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុ។ នៅទូទាំងពិភពលោក និងក្នុងប្រទេសដែលមានសេដ្ឋកិច្ចជឿនលឿន អតិផរណាកំពុងដំណើរការក្នុងអត្រាខ្ពស់បំផុតចាប់តាំងពីឆ្នាំ ២០០៨។ នៅក្នុងទីផ្សារដែលកំពុងរីកចម្រើន និងប្រទេសកំពុងអភិវឌ្ឍន៍ វាបានឈានដល់អត្រាខ្ពស់បំផុតចាប់តាំងពីឆ្នាំ

២០១១។ ប្រទេសដែលមានសេដ្ឋកិច្ចកំពុងរីកចម្រើន និងកំពុងអភិវឌ្ឍន៍ជាច្រើនកំពុងកែប្រែគោលនយោបាយដើម្បីទប់ទល់នឹងសម្ពាធអតិផរណា មុននឹងការងើបឡើងវិញពេញលេញ។

ដូច្នេះហើយ គណៈគ្រប់គ្រងយល់ឃើញថា សកម្មភាពរបស់ក្រុម និងធនាគារអាចរងផលប៉ះពាល់ខ្លះៗ ប៉ុន្តែនឹងមិននាំទៅរកបញ្ហាដែលគួរឲ្យកត់សំគាល់នោះទេ ដោយសារទំហំនៃប្រតិបត្តិការកម្រិតប្រាក់ចំណេញបច្ចុប្បន្ន និងលំហូរសាច់ប្រាក់ងាយស្រួលរបស់ក្រុម និងធនាគារ។

## ខ. កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

### ១. ការវិភាគពីលក្ខខណ្ឌនៃតម្រូវការ និងការផ្គត់ផ្គង់

បន្ទាប់ពីការស្ទុះងើបឡើងវិញដ៏រឹងមាំនៅឆ្នាំ ២០២១ សេដ្ឋកិច្ចពិភពលោកកំពុងឈានចូលដល់ការធ្លាក់ចុះគួរឱ្យកត់សម្គាល់ ចំពេលមានការគំរាមកំហែងថ្មីៗពីការប្រែប្រួលនៃមេរោគកូវីដ-១៩ និងការកើនឡើងនៃអតិផរណា បំណុល និងវិសមភាពប្រាក់ចំណូលដែលអាចបង្កគ្រោះថ្នាក់ដល់ការងើបឡើងវិញនៅក្នុងសេដ្ឋកិច្ចដែលកំពុងរីកចម្រើន និងកំពុងអភិវឌ្ឍន៍។

ដូច្នេះ ដើម្បីធានាបាននូវកំណើនប្រកបដោយនិរន្តរភាពជាមួយនឹងស្ថានភាពបែបនេះ ធនាគារនៅតែបន្តអភិវឌ្ឍកាន់តែច្រើនឡើងថែមទៀតសម្រាប់បណ្តាញឌីជីថលរបស់ធនាគារដូចខាងក្រោម៖

- ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានតម្លើង version សេវាធនាគារចល័តពី ២.០ ទៅ ២.៥ ដើម្បីធ្វើឲ្យប្រសើរឡើងនូវបទពិសោធន៍ធនាគារឌីជីថល របស់អតិថិជន និងការបន្ថែមមុខងារថ្មីៗ។
- ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានដាក់ឲ្យដំណើរការ ជាផ្លូវការនូវសេវាខេអេចឃ្យូអរ "PPCBank KHQR Service"។ ការធ្វើឲ្យប្រសើរឡើងនូវសេវាខេអេចឃ្យូអរ ភីភីស៊ីប៊ែង នឹងអនុញ្ញាតឲ្យអតិថិជនទទួលយកនូវការទូទាត់ពីធនាគារ, គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និង Wallets ផ្សេងៗ។ ខេអេចឃ្យូអរ ត្រូវបានបង្កើតឡើងសម្រាប់ការទូទាត់វាយ ដែលតម្រូវឲ្យមានតែឃ្យូអរតែមួយគត់សម្រាប់ទទួលការទូទាត់ពី Mobile Apps នៅក្នុងប្រទេសកម្ពុជា បានធ្វើឲ្យការទូទាត់តាមរយៈឃ្យូអរកាន់តែមានភាពសាមញ្ញ និងងាយស្រួលសម្រាប់ទាំងអតិថិជន និងពាណិជ្ជករទូទាត់វាយ (Merchants)។
- ដើម្បីធ្វើឲ្យកាន់តែប្រសើរឡើងនូវផលិតផល និងសេវារបស់ខ្លួន ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានបន្ថែមមុខងារប្រតិបត្តិការចំនួន ០៣ សម្រាប់ការទូទាត់បន្ថែមលើសេវាធនាគារចល័ត

(PPCBank Mobile Banking) និងសេវាធនាគារតាមអ៊ីនធើណែត (Corporate Internet Banking) ដូចជា៖

- ការបង់ភាគទានបេឡាជាតិសន្តិសុខសង្គម (ប.ស.ស)
- ការទូទាត់ជាមួយពាណិជ្ជករទូទាត់វាយតាមអនឡាញ និង
- ការបន្ថែម KHQR Code សម្រាប់ការទូទាត់។

### ២. ការវិភាគពីការឡើងចុះនៃថ្លៃវត្ថុធាតុដើម

ការឡើងចុះនៃថ្លៃវត្ថុធាតុដើមមិនមានផលប៉ះពាល់ដល់ធនាគារឡើយ ។

### ៣. ការវិភាគលើពន្ធ

ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួន ស្ថិតនៅក្រោមច្បាប់ស្តីពីពន្ធដារនៃព្រះរាជាណាចក្រកម្ពុជា។ ដូច្នេះធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួនត្រូវមានកាតព្វកិច្ចបង់ពន្ធដូចបានកំណត់ក្នុងបទប្បញ្ញត្តិស្តីពីពន្ធដាររបស់ព្រះរាជាណាចក្រកម្ពុជា។

### ៤. ការវិភាគលើធាតុដែលខុសពីធម្មតា និងធាតុវិសាមញ្ញ

សេដ្ឋកិច្ចពិភពលោកកំពុងមានការធ្លាក់ចុះគួរឱ្យកត់សម្គាល់ ចំពេលមានការគំរាមកំហែងថ្មីៗពីការប្រែប្រួលនៃមេរោគកូវីដ-១៩ រួមទាំងការកើនឡើងនៃអតិផរណា អាចមានផលប៉ះពាល់ដល់លទ្ធផលហិរញ្ញវត្ថុរបស់ធនាគារ។

## គ. ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

ក្នុងត្រីមាសទី២ ឆ្នាំ២០២២ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក មានការកើនឡើងនៃចំណូលដែលមានចំណូលការប្រាក់សុទ្ធសរុប ៥១.៤២៦លានរៀល ដែលស្មើនឹងការកើនឡើង ៨,៧% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២១។

## ឃ. ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ

ស្ថានភាពចំហនៃរូបិយប័ណ្ណបរទេស ត្រូវបានត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់ជាប្រចាំតាមបទបញ្ញាត្តិ ដើម្បីអាចវាស់វែង និងធានាថាវានឹងមិនធ្វើឲ្យប៉ះពាល់ដល់និរន្តរភាពនៃប្រាក់ចំណេញរបស់ធនាគារ។

ពាក់ព័ន្ធនឹងអត្រាការប្រាក់ធនាគារកំណត់អត្រាការប្រាក់ថេរសម្រាប់ប្រាក់បញ្ញើរ និងប្រាក់កម្ចីរបស់ខ្លួនសម្រាប់ប្រតិបត្តិការអាជីវកម្ម។ ដូច្នេះធនាគារមិនមានទទួលរងហានិភ័យជាសារវន្តទាក់ទងនឹងអត្រាការប្រាក់មកលើលទ្ធផលនៃប្រតិបត្តិការអាជីវកម្មធនាគារនោះទេ ។

ឥទ្ធិពលនៃថ្លៃទំនិញ មិនមានផលប៉ះពាល់មកលើលទ្ធផលប្រតិបត្តិរបស់ធនាគារឡើយ ។

## ង. ផលប៉ះពាល់អតិផរណា

អតិផរណាជាមធ្យមមានកម្រិត ៦,៥% ខ្ពស់ជាងឆមាសទី២ ឆ្នាំ២០២១ (៣,៤%) ដោយសារកំណើនថ្លៃក្រុមទំនិញ និងសេវាពាក់ព័ន្ធនឹងប្រេងឥន្ទនៈ និងម្ហូបអាហារ។ ជាមួយអត្រាអតិផរណានេះមិនមានផលប៉ះពាល់ណាមួយជាសារវន្ត មកលើលទ្ធផលប្រតិបត្តិការអាជីវកម្មរបស់ធនាគារឡើយ។

## ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងហិរញ្ញវត្ថុ របស់រដ្ឋាភិបាល

យោងតាមប្រកាសរបស់អគ្គនាយកដ្ឋានពន្ធដារ (GDT) ស្តីពីការណែនាំអនុវត្តការលើកទឹកចិត្តពន្ធកាត់ទុក និងពន្ធលើចំណេញមូលធនដល់អ្នកវិនិយោគមូលបត្ររដ្ឋ អ្នកវិនិយោគត្រូវបានទទួលការបន្ថយពន្ធកាត់ទុក ៥០% លើការប្រាក់ដែលបានមកពីការកាន់កាប់ និង/ឬការទិញ-លក់មូលបត្ររដ្ឋសម្រាប់រយៈពេល៣ឆ្នាំ ដោយអនុលោមតាមអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២២។ អ្នកវិនិយោគត្រូវបានលើកលែងពន្ធលើចំណេញមូលធន ចំពោះការទិញ និងការជួញដូរមូលបត្រ។ ពន្ធកាត់ទុកលើការប្រាក់នៃមូលបត្ររដ្ឋ ត្រូវកំណត់តាមអត្រាដូចខាងក្រោម៖

ក. អត្រា ៦% ចំពោះការទូទាត់ការប្រាក់ឲ្យដល់អ្នកជាប់ពន្ធនិវាសនជន ដូចគ្នានឹងការប្រាក់ដែលធនាគារក្នុងស្រុកបង់ឲ្យទៅអ្នកជាប់ពន្ធនិវាសនជន ដែលមានគណនីបញ្ញើមានកាលកំណត់ស្របតាមមាត្រា២៥ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ។

ខ. អត្រា ១៤% ចំពោះការទូទាត់ការប្រាក់ឲ្យដល់អ្នកជាប់ពន្ធអនិវាសនជន។

**ហត្ថលេខាអភិបាលរបស់ធនាគារភ្នំពេញពាណិជ្ជ ម.ក**

ថ្ងៃទី១១ ខែសីហា ឆ្នាំ២០២២

បានអាន និងឯកភាព




លោក YIM. Yong Taick

ប្រធានក្រុមប្រឹក្សាភិបាល

PPCBank